
ទាយាទពស់
Successor of snake
Reading Books

## Successor of snake

កាលដែល**នាងនី**ឆ្លាយពោះនោះ មានកូនពស់ជាច្រើនបានវារចេញពីពោះរបស់នាង ខ្លះវារចូលទឹក ខ្លះវារចូលដីក្រហែង ខ្លះត្រូវប្ដី**នាងនី**កាប់ចិញ្ច្រាំឥតត្រាប្រណី តែក្នុងចំណោមកូនពស់ទាំងអស់មានកូនពស់មួយមានភ័ព្វសំណាងល្អជាងគេ វាបានលូនទៅជ្រកនៅក្រោមផ្ទាំងថ្មមួយដែលជាទីកំបាំងដ៏សុខសាន្តរបស់វា ។

រឿងកូន**ពស់កេងកង**សូមស្លេះត្រឹមនេះសិនចុះ ហើយមកតាមដានជីវិតដ៏សែនជូរចត់របស់នាង**សូរិយា**វិញម្ដង តើនាងត្រាំត្រាចិត្តយ៉ាងណាពេលដែលរស់នៅជាមួយនឹងនាង**ល្វាចេក**ជាម្ដាយចុង ។ នាងម្ដាយចុងនោះ ជាស្រីដែលមានចិត្តអាក្រក់ ពូកែច្រណែនឈ្នានីសនាង**សូរិយា**ណាស់ ហើយនាងតែងតែស្ដីបន្ទោសឱ្យនាង**សូរិយា**ជារៀងរាល់ថ្ងៃ ។ ឪពុករបស់នាងក៏ដឹងអំពីរឿងនេះដែរ លោកអាណិតកូនស្រីរបស់លោកណាស់ តែមិនដឹងដោះស្រាយដោយវិធីណា ។

ថ្លែងពីកូន**ពស់កេងកង**ដែលរស់នៅក្នុងរូងភ្នំបានសេចក្ដីសុខស្រួលណាស់ វារស់នៅក្នុងល្អាងនោះយូរៗទៅកាន់តែធំទៅៗ ចេះទាំងក្លាយខ្លួនឱ្យទៅជាមនុស្សយ៉ាងស្រស់សង្ហាកម្ររកប្រុសណាមកប្រដូចបាន ។ កំលោះរូបនេះមានចិញ្ចៀនពេជ្រមួយវង់ដែលរលាយចេញពីគុជក្នុងពោះ ។ ថ្ងៃនេះគេបានចេញមកយកខ្យល់អាកាសនៅខាងក្រៅដោយជិះទូកលេងកម្សាន្តចំពេលដែលនាង**សូរិយា**ត្រូវឪពុកឱ្យចាកចេញពីផ្ទះបានមករស់នៅក្នុងព្រៃយ៉ាងស្ងាត់ជ្រងំជាមួយនឹងអ្នកបម្រើមួយចំនួនដែលលោកសេដ្ឋីបញ្ជូនមកចាំថែរក្សា ។ ចៅមាណពកំពុងតែជិះទូកកម្សាន្តក៏ស្រាប់តែឮសំឡេងមនុស្សស្រីច្រៀងយ៉ាងពីរោះធ្វើឱ្យគេចម្លែកក្នុងចិត្តគិតថា "នៅក្នុងព្រៃស្ងាត់បែបនេះ ម្ដេចក៏មានមនុស្សមករស់នៅដែរហ្ន៎?" បន្តិចក្រោយមកស្រាប់តែបាត់សំឡេងច្រៀងបែរជាឮសំឡេងស្រែកឱ្យគេជួយទៅវិញ ព្រោះនាងកំពុងលង់ទឹក ។ មិនបង្អង់យូរមាណពក៏ជិះទូកទៅកន្លែងសំឡេងនោះបានឃើញពពុះព្រុលៗចេញពីក្នុងទឹក ហើយមាណពស្ទុះហក់ចុះទៅក្នុងទឹកដើម្បីជួយសង្គ្រោះជីវិតនាងដោយស្រង់នាងមកដាក់លើទូករបស់ខ្លួន ។



ចំណែកនៅឯគេហដ្ឋានរបស់នាង**សូរិយា**ឯណោះវិញ លោកយាយម៉ៃដោះកំពុងតែដើររកនាងពេញផ្ទះរហូតដល់កំពង់ទឹក តែមិនបានឃើញនាងឡើយ ឃើញតែផ្តិលទឹករបស់នាងតែប៉ុណ្ណោះ ធ្វើឱ្យគាត់មានការព្រួយបារម្ភរឹតតែខ្លាំង ។ លោកយាយ និងអ្នកផ្ទះបាននាំរឿងនេះទៅជម្រាបលោកសេដ្ឋី ។ ឯលោកសេដ្ឋីជ្រាបពីដំណឹងអកុសលនេះភ្លាមក៏ភ័យឆោឡោប្រើបរិវារទៅជួយរកនាងនៅឯព្រៃ ។ នៅលើទូកមាណព បន្ទាប់ពីនាងដឹងខ្លួនវិញហើយក៏ឃើញបុរសរូបស្អាតកំពុងតែអង្គុយក្បែរនាងធ្វើឱ្យនាងមានការអៀនខ្មាសយ៉ាងខ្លាំង ហើយក៏ងើបឡើងសួរទៅមាណពនោះថា "តើអ្នកបានជួយខ្ញុំមែនទេ?" មាណពតបថា "បាទអ្នកនាង" ។ **សូរិយា**ក៏បានអរគុណបុរសនោះហើយចង់ត្រលប់ទៅផ្ទះវិញ ។ តែបុរសនោះបានយកអាវធំរបស់គេមកដណ្តប់ឱ្យនាង ព្រោះនាងត្រូវទឹកជូរច្រេះគីរងាខ្លាំងណាស់ ។